មេដឹកនាំខ្មែរក្រោម ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម និងជាអតីតសមាជិកព្រឹទ្ធសភា ឯកឧត្តម ថាច់ សេដ្ឋា ដឹកនាំគណៈប្រតិភូ ជួបសវនការជាមួយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម ហោ ណាំហុង នាល្ងាចថ្ងៃទី១៩ ខែសីហា ព.ស.២៥៥៨ គ.ស.២០១៤

Khmer Krom leader, KKC president and former Senator Thach Setha leads a delegation to meet with DPM and FAIC Minister Hor Namhong on petition to summon Vietnam's ambassador to provide clarification on Kampuchea Krom at the Ministry.



សហគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY

LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ [illegible] ស.ខ.ក.ក.

ញត្តិ

គោរពជូន

ឯកឧត្តម ហោ ណាំហុង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

**កម្មវត្ថុ:** សំណើកោះអញ្ជើញឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា ធ្វើកំណត់ការទូត

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជំរាបជូនឯកឧត្តម មេត្តាជ្រាបថា កាលពីថ្ងៃទី០៦ ខែមិថុនាឆ្នាំ២០១៤ លោក ត្រឹង វ៉ាន់ ធុង បានថ្លែងប្រាប់វិទ្យុអាស៊ីសេរីផ្នែកភាសាខ្មែរថា *បារាំងមិនបានកាត់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យវៀតណាមទេ តែកម្ពុជាក្រោមជាទឹកដីរបស់វៀតណាមតាំងពីយូរយារណាស់មក ហើយក៏មិនមានបាត់បង់ទឹកដីគ្មានអ្វីជាមូលដ្ឋានទេ គ្មានអ្វីជាភស្តុតាងទេ។*

ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ ស្ថានទូតវៀតណាមបានចេញថ្លែងការណ៍ថ្កោលទោសការធ្វើបាតុកម្មរបស់ សហព័ន្ធនិស្សិត បញ្ញវន្តកម្ពុជានៅមុខស្ថានទូតវៀតណាមនាព្រឹកថ្ងៃទី០៨កក្កដា២០១៤ ហើយបានគាំទ្រដល់ការថ្លែងរបស់អ្នកនាំពាក្យខាងលើ។

ថ្ងៃទី១០ខែកក្កដាឆ្នាំ២០១៤ អ្នកនាំពាក្យក្រសួងការបរទេសវៀតណាមបានប្រាប់អ្នកកាសែតនៅទីក្រុងហាណូយមានលក្ខណៈគាំទ្រដល់អ្នកនាំពាក្យរបស់ស្ថានទូតវៀតណាមបន្ថែមទៀត។

ថ្ងៃទី២១ខែកក្កដា ឆ្នាំ២០១៤ សិស្ស និស្សិត យុវជន យុវនារី ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរជាងមួយម៉ឺននាក់ បានដាក់ញត្តិតវ៉ាឲ្យរដ្ឋាភិបាលវៀតណាម សុំទោស ក្នុងការនិយាយបំភ្លៃប្រវត្តិសាស្ត្រខ្មែរនេះ ក៏គ្មានអ្នកណាម្នាក់នៃស្ថានទូតវៀតណាមចេញមកទទួលញត្តិរបស់យើងខ្ញុំដែរ។

ជាបន្តបន្ទាប់ អ្នកនាំពាក្យរបស់ស្ថានទូតវៀតណាម ឈ្មោះត្រឹង វ៉ាន់ ធុងនេះ នៅតែនិយាយប្រាប់បណ្តាញផ្សព្វផ្សាយក្នុងលក្ខណៈមើលងាយប្រជាពលរដ្ឋខ្មែរថា មិនទទួលស្គាល់ញត្តិ មិនទទួលស្គាល់ការធ្វើបាតុកម្មរបស់ប្រជាពលរដ្ឋខ្មែរទេ ថែមទាំងបានហៅក្រុមបាតុករខ្មែរថា ជាក្រុមមួយក្តាប់តូច ថែមទៀតផង។

ក្នុងការគោរពចំពោះមិត្តភាពប្រទេសជិតខាងល្អរវាងកម្ពុជា-វៀតណាម យើងខ្ញុំបានតវ៉ាដោយសន្តិវិធី ដើម្បីឲ្យរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រខ្មែរ តែវៀតណាមនៅតែធ្វើមិនដឹងមិនឮដដែល។

ទីស្នាក់ការផ្ទះលេខៈ ៧២ ផ្លូវលេខៈ ៣១៦A [illegible] រាជធានីភ្នំពេញ
ទូរស័ព្ទលេខៈ (៨៥៥) ១២ ៤០៨ ៨៧២ / ៩៣ ៥៣ ៥៣ ០៦
E-mail: thachsetha13@gmail.com Website: http/khmerkromngo.org

សេចក្តីដូចបានជំរាបជូនខាងលើ យើងខ្ញុំតំណាងបាតុករ សូមស្នើឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មេត្តាកោះអញ្ជើញឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា មកធ្វើកំណត់ការទូត ដើម្បីបញ្ចប់ការបំភ្លៃប្រវត្តិសាស្ត្រខ្មែរពីសំណាក់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមតទៅទៀត និងជៀសវាងការភ័ន្តច្រឡំក្នុងការសិក្សារៀនសូត្រ និងស្រាវជ្រាវរបស់សិស្ស និស្សិតតទៅមុខ តាមការគួរ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី១១ខែសីហា ឆ្នាំ២០១៤

តំណាងបាតុករ

| | |
|---|---|
| ១- ឯកឧត្តម ថាច់ សេដ្ឋា | ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម |
| ២- ភិក្ខុ ឡាយ ឡាត | អគ្គលេខាធិការសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម |
| ៣-លោក សាន ណារិទ្ធិ ប្រធាន | iCambodia_យុវជនដើម្បីប្រជាធិបតេយ្យ |
| ៤-លោក តឹម សុវណ្ណារិទ្ធ | ប្រធាន I Love Cambodia Hot News |
| ៥-លោក សន ចាន់ដារ៉ា | តំណាងយុវជនខ្មែរមហានគរ |
| ៦-លោក ខេព ណារិន | អនុប្រធានយុវជនដើម្បីសន្តិភាព |
| ៧-លោកយុន គុណា | ប្រធាន ក្លឹបសំឡេងយុវជនខ្មែរ_អន្តរជាតិ |
| ៨-លោក វិល្លៀម ហាណេស គីវណ្ណា | ប្រធានចលនាប្រជាធិបតេយ្យ ជាតិនិយម |
| ៩-លោក ជាសុទ្ធី | អនុប្រធានចលនាយុវជនស្ម័គ្រប្រជាធិបតេយ្យខ្មែរ |
| ១០-លោក ឈួន ភក្តិ | ប្រធានយុវជនឯករាជ្យ សង្គ្រោះបឋម (IVFAT) |
| ១១-លោក អន លីម៉ា | ប្រធានបណ្តាញបុរសខ្មែរ ដើម្បីប្រជាធិបតេយ្យ |
| ១២-កញ្ញា សុខ សុធា | អ្នកសម្របសម្រួលសម្ព័ន្ធយុវជនខ្មែរដើម្បីប្រជាធិបតេយ្យ |

សូមភ្ជាប់ជូនឯកសារប្រវត្តិសាស្ត្រកម្ពុជាក្រោមសង្ខេប០១ច្បាប់






សហាគមន៍ខ្មែរកម្ពុជាក្រោម KKC (The Khmer Kampuchea Krom Community)
Website:www.KhmerKromngo.org